01575011

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
21 / 06 / 2018
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E460/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨

**ជូនចំពោះ៖** អង្គភាពពេទ្យ
អង្គភាពគាំពារសាក្សី និងអ្នកជំនាញ
ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ដីកាបង្គាប់ឲ្យធ្វើតេស្តបញ្ហាស្មារតីរបស់ជនជាប់ចោទប្រចាំត្រីមាស និងកាលវិភាគនៃការធ្វើតេស្ត

១. នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាកំណត់ពេលវេលាបន្តការធ្វើតេស្តលើបញ្ហាស្មារតីរបស់ជនជាប់ចោទនីមួយៗប្រចាំត្រីមាស តាមរយៈការធ្វើតេស្តត្រួសៗលើមុខងារបញ្ហាស្មារតី ("ការធ្វើតេស្ត AMT") សម្រាប់រយៈពេលចាប់ពីខែកញ្ញា ឆ្នាំ ២០១៧ ដល់ខែ មិថុនា ឆ្នាំ ២០១៨ (ឯកសារ E389/5/2)។

២. នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទនីមួយៗក្នុងការចូលរួមសវនាការ(ឯកសារ E460/4 សម្រាប់ នួន ជា ឯកសារ E460/5 សម្រាប់ ខៀវ សំផន)។ សេចក្តីសម្រេចទាំងនេះគឺផ្អែកលើរបាយការណ៍របស់ វេជ្ជបណ្ឌិត CHAN Kin Ming និង វេជ្ជបណ្ឌិត ហួត លីនណា ("អ្នកជំនាញ")

ដែលត្រូវបានចាត់តាំង អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង ដើម្បីធ្វើការវាយតម្លៃវេជ្ជសាស្ត្រ និងចិត្តសាស្ត្រទៅលើជនជាប់ចោទនីមួយៗ (ឯកសារ E460)។ នៅក្នុងសេចក្តីសម្រេចទាំងនោះ អង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទ មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយបង្គាប់ឱ្យបន្តធ្វើតេស្ត ATM ពួកគាត់ យ៉ាងហោចណាស់មួយត្រីមាសម្តង និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការធ្វើតេស្តនេះជូនអង្គជំនុំជម្រះ (ឯកសារ E460/4 ផ្នែកសម្រេចសេចក្តី, ឯកសារ E460/5 ផ្នែកសម្រេចសេចក្តី)។

៣. ទាក់ទិននឹងការធ្វើតេស្ត AMT ដែលពីមុនបានកំណត់ពេលអនុវត្តចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៨ អង្គជំនុំជម្រះបានទាក់ទងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៨។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជូនដំណឹងដល់អង្គជំនុំជម្រះថា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (“មន្ទីរពេទ្យ”) ដែលផ្តល់សេវាកម្មតាមកិច្ចសន្យាដល់អង្គភាពពេទ្យ អ.វ.ត.ក. នោះ បានសម្រេចអនុវត្តការធ្វើតេស្ត ATM នៅក្នុងខែ ឧសភា ដោយមូលហេតុមានកម្មវិធីការងារមមាញឹកនៅក្នុងខែ មិថុនា។ វេជ្ជបណ្ឌិត ចក ធីតា និង វេជ្ជបណ្ឌិត ឈួរ ចាន់ណារា បានធ្វើតេស្ត AMT ទៅលើជនជាប់ចោទទាំងពីរ នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៨។ អង្គជំនុំជម្រះបានទទួលលទ្ធផលនៃការធ្វើតេស្ត AMT ទៅលើជនជាប់ចោទនីមួយៗ នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ (ឯកសារ E10/390.1 សម្រាប់ នួន ជា, ឯកសារ E13/387.1 សម្រាប់ ខៀវ សំផន) ។ លទ្ធផលនៃការធ្វើតេស្ត AMT ពុំបានបង្ហាញឱ្យឃើញថា ជនជាប់ចោទនីមួយៗមានការចុះខ្សោយផ្នែកបញ្ញាស្មារតីនោះទេ (សូមមើល ឯកសារ E460 កថាខណ្ឌ ៣)។

៤. ដោយរម្លឹកឡើងវិញនូវដីកាបង្គាប់របស់អង្គជំនុំជម្រះឱ្យបន្តការធ្វើតេស្ត ATM និងដើម្បីធានាឱ្យមានការវាយតម្លៃទៀងទាត់ទៅលើជនជាប់ចោទទាំងពីរនេះ រហូតដល់ថ្ងៃចេញសាលក្រមនៃសំណុំរឿង០០២/០២ នោះ អង្គជំនុំជម្រះបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជួយសម្របសម្រួល និងកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើតេស្តប្រចាំត្រីមាសបន្តបន្ទាប់ទៀត នៅក្នុងអំឡុងពេលដូចខាងក្រោម៖

- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៨

- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨
- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៩
- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៩

៥. អង្គជំនុំជម្រះយល់ឃើញថា ជាការសមស្របដែលសាស្ត្រាចារ្យ ចក ធីតា និងវេជ្ជបណ្ឌិត ឈួរ ចាន់ណារា បន្តអនុវត្តតេស្តទាំងនេះរួមគ្នា។ ស្របជាមួយយោបល់របស់ វេជ្ជបណ្ឌិត CHAN Kin Ming អង្គជំនុំជម្រះបង្គាប់ឱ្យធ្វើការផ្លាស់ប្តូរតេស្តនោះជាប្រចាំ ដើម្បីកុំឱ្យលទ្ធផលដែលទទួលបាន ទទួលរងនូវផលប៉ះពាល់ដោយសារភាពស៊ាំទៅនឹងតេស្តនោះ (ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៣៥-៣៦)។ អង្គជំនុំជម្រះ ក៏បង្គាប់ឱ្យអង្គភាពពេទ្យ ត្រូវធានាថា ការធ្វើតេស្ត AMT ត្រូវអនុវត្តតាមកាលបរិច្ឆេទដែលបានកំណត់នៅក្នុងដីកាបង្គាប់នេះ និងដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនូវលទ្ធផលនៃការធ្វើតេស្ត AMT លើជនជាប់ចោទនីមួយៗ ឱ្យបានឆាប់តាមដែលអាចធ្វើបាន ក្រោយពេលធ្វើតេស្តម្តងៗ។